Hà Tiên Vegas
ENTERTAINMENT RESORT

Issue 6 September 2017

# Staff Newsletter

## បុគ្គលិកឆ្នើមប្រចាំខែកក្កដា

កាស៊ីណូ ហាទៀង វីហ្គាស អេនធើធេនមេន រីហ្សតតែងតែប្រារព្ធធ្វើកម្មវិធីប្រគល់វិញ្ញាបនប័ត្របញ្ជាក់អំពីបុគ្គលិកដែលមានស្នាដៃឆ្នើមក្នុងការងារប្រចាំខែនិមួយៗ និងទឹកប្រាក់ចំនួន ៥០ ដុល្លារ សំរាប់បុគ្គលិកធម្មតា ព្រមទាំង ១០០ដុល្លារសំរាប់បុគ្គលិក ថ្នាក់គ្រប់គ្រង។ លើសពីនេះយើងមានរៀបចំកម្មវិធីញ៉ាំម្ហូប អាហាររួមជាមួយគ្នាក្រោយពីបញ្ចប់កម្មវិធីប្រគល់បណ្ណសរសើរដល់បុគ្គលិករបស់យើង។ ក្រុមហ៊ុនសង្ឃឹមថាបុគ្គលិកដែលមិនទាន់មានឱកាសទទួលបានបណ្ណសរសើរនេះនឹងខិតខំប្រឹងប្រែងបន្តទៀតដោយមិនត្រូវអស់សង្ឃឹមឡើយដើម្បីទទួលបានដូចបុគ្គលិកដែលធ្លាប់មានស្នាដៃល្អក្នុងការងារ ។រូបថតទាំងនេះបង្ហាញអំពីសកម្មភាពដែលក្រុមហ៊ុនបានប្រារព្ធធ្វើសំរាប់ខែកក្កដា ឆ្នាំ២០១៧កន្លងទៅមានរាយនាមដូចខាងក្រោម៖

| | |
|---|---|
| ១. ង៉ែត លឿន | ផ្នែកសន្តិសុខ |
| ២. ប៉ោ សឿន | ផ្នែកផ្ទះបាយ |
| ៣. សៀង ឆេងរ៉ុន | ផ្នែកថែសួន |
| ៤. ប៉េង ធីណា | ផ្នែកហ្គេម្មីញ |
| ៥. វ៉ែន ធីតា | ផ្នែកហ្គេម្មីញ |
| ៦. ប៉ែន សុព៌ពិសី | ផ្នែកហ្គេមុីញ |
| ៧. ស៊ុន ធឿន | ផ្នែកខេច |
| ៨. ជាវ ដាណា | អនឡាញហ្គេមុិញ |
| ៩. កែប វិចិត្រ | ផ្នែកហ្គេមុីញ |


























សូមជូនដំណឹងដល់បុគ្គលិកទាំងអស់ដែលបានធ្វើការនៅក្នុងកាស៊ីណូឲ្យបានជ្រាបថា៖ សូមបងប្អូនទាំងអស់ដែលស្នាក់នៅបន្ទប់របស់កាស៊ីណូមេត្តារក្សាសណ្តាប់ធ្នាប់ និងសុជីវធម៌ក្នុងការស្នាក់នៅឲ្យបានល្អដូចជាការទុកដាក់ស្បែកជើងទុកដាក់សំលៀកបំពាក់ឲ្យបានត្រឹមត្រូវ មិនត្រូវស្រែកឡូឡាឬចាក់បទចំរៀងក្នុងបន្ទប់នៅពេលដែលមិត្តភក្ររួមបន្ទប់កំពុងគេងនោះទេដែលអាចបង្ករឲ្យមានការរំខានដល់ដំណេករបស់ពួកគាត់។សីលធម៌ល្អ សុជីវធម៌ល្អនាំមកនូវសេចក្តីថ្លៃថ្នូរសំរាប់អ្នករាល់គ្នា។





## អ្នកគ្រប់គ្រងផ្នែកសាងសង់ថ្មី (តពីទំព័រទី១)

កន្លែងដែលគាត់ចូលចិត្តនៅប្រទេសកម្ពុជាគឺប្រាសាទអង្គរវត្តនិងក្រុងកែប ។ គាត់ចូលចិត្តអង្គរវត្តពីព្រោះគាត់គិតថាពិតជារំភើបខ្លាំងណាស់ដែលដើរកំសាន្តមើលវប្បធម៌បុរាណ។ គាត់ចូលចិត្តក្រុងកែបមិនមែនពីព្រោះតែឆ្នេរខ្សាច់ ឬក្តាមនោះទេ។ ក្រុងកែបគឺពិតជាធ្វើអោយគាត់ចាប់អារម្មណ៍ណាស់ពីព្រោះជាអតីតផ្ទះបារាំងចាស់។ គ្មានអ្វីគួរអោយភ្ញាក់ផ្អើលនោះទេ គាត់គឺជាអ្នកគ្រប់គ្រងផ្នែកសាងសង់ !
វត្ថុម្យ៉ាងដែលធ្វើអោយលោក ម៉ាក ជាមនុស្សមានតែម្នាក់ក្នុងចំណោមបុគ្គលិកកាស៊ីណូ ហាទៀងវេហ្គាស់នោះគឺ កងបបូរមាត់របស់គាត់។ គាត់បានដាក់វា១០ឆ្នាំហើយ ។នៅពេលដែលគាត់ចោះបបូរមាត់រួចរាល់ហើយពិតជាឈឺចាប់ខ្លាំងណាស់ប៉ុន្តែវាមិនមានការឈឺចាប់អ្វីទៀតឡើយ ។កំឡុងពេលនោះពិតជាកម្រមានណាស់នៅក្នុងចំណោមប្រជាជនកម្ពុជាដែលថាគ្រឿងអលង្ការបែបនេះគឺសាមញ្ញណាស់ទៅហើយក្នុងចំណោមមនុស្សដែលមានភាពឆ្នៃប្រឌិតក្នុងសហរដ្ឋអាមេរិក។ ហើយលោកម៉ាកគឺមានភាពច្នៃប្រឌិត។ គាត់មិនត្រឹមតែសាងសង់អាគារបាននោះទេហើយថែមទាំងអាចគូរគំនូរនិងចម្លាក់បានទៀតផង ។ អ្នកអាចមើលការលើកនូវឧទាហរណ៍ដូចខាងក្រោម។ លោកម៉ាកគឺរំភើបណាស់ដែលបានក្លាយជាបុគ្គលិករបស់កាស៊ីណូហាទៀងវេហ្គាស់។